# និយ័តករគណនេយ្យនិងសវនកម្ម

## ព្រឹត្តិបត្រព័ត៌មានប្រចាំខែមេសា ឆ្នាំ២០២៤

លេខ:០០៤


សេចក្តីសង្ខេបព័ត៌មាននិងព្រឹត្តិការណ៍សំខាន់ៗប្រចាំខែមេសារបស់**និយ័តករគណនេយ្យនិងសវនកម្ម** នៃ**អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** រួមមានដូចខាងក្រោម៖

## ព័ត៌មានថ្មីៗ


សិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចគណនេយ្យនិងសវនកម្មនិងបទប្បញ្ញត្តិពាក់ព័ន្ធ"(ZOOM)សូមអាននៅទំព័រ..............១

កិច្ចប្រជុំជាមួយតំណាងអគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានពន្ធដារ"សូមអាននៅទំព័រ...............២

កិច្ចប្រជុំការងារបច្ចេកទេសនៃអង្គភាពក្រោមឱវាទ អ.ស.ហ. សូមអាននៅទំព័រ...............២

កិច្ចប្រជុំជាមួយតំណាងក្រុមហ៊ុនគណនេយ្យនិងសវនកម្ម សូមអាននៅទំព័រ...............៣

កិច្ចប្រជុំពិភាក្សាស្តីពីការបង្ហាញ "ការបង្វិលសងអាករលើតម្លៃបន្ថែម (VAT Refund) ក្នុងច្បាប់ ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ" សូមអាននៅទំព័រ...............៣

វគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដារបាយការណ៍ទាក់ទនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុន តូចនិងមធ្យម" CIFRS for SMEs សូមអាននៅទំព័រ...............៤

ជួបសម្តែងការគួរសមនិងពិភាក្សាការងារជាមួយគណៈប្រតិភូសាកលវិទ្យាល័យពាណិជ្ជសាស្ត្រអេស៊ីលីដា សូមអាននៅទំព័រ ...............៤

កិច្ចប្រជុំពិភាក្សាទ្វេភាគីជាមួយក្រុមការងារ "ឍ"សេវាហិរញ្ញវត្ថុមិនមែនធនាគារផ្នែកឯកជននៃសភាពាណិជ្ជកម្មកម្ពុជា សូមអាននៅទំព័រ ...............៥

កិច្ចប្រជុំស្តីពីការបូកសរុបការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៤ សូមអាននៅទំព័រ ...............៥

កិច្ចប្រជុំបច្ចេកទេសបន្តជាមួយក្រុមហ៊ុន Big4 និងវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា សូមអាននៅទំព័រ.....៦

សិក្ខាសាលាផ្សព្វផ្សាយ "ប្រកាសស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម និងការស្នើសុំអាជ្ញាបណ្ណតាមប្រព័ន្ធអនឡាញ" លើកទី៣សូមអាននៅទំព័រ ...............៦

**កិច្ចប្រជុំពិភាក្សាស្តីពីការកត់ត្រាការបង្វិលសងអាករលើតម្លៃបន្ថែម** (VAT Refund) " លើកទី៣សូមអាននៅទំព័រ .......៧

កិច្ចពិភាក្សាប្រចាំឆ្នាំនិងលក្ខខណ្ឌតម្រូវដើម្បីក្លាយជាសមាជិកពេញសិទ្ធរបស់សហព័ន្ធ គណនេយ្យករអន្តរជាតិ សូមអាននៅទំព័រ ...............៧

**កិច្ចពិភាក្សាជាមួយសមាគមធានារ៉ាប់រងកម្ពុជាស្តីពីផែនការសកម្មភាពអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាលេខ ១៧ "កិច្ចសន្យាធានារ៉ាប់រង" និង លេខ ៩ "ឧបករណ៍ហិរញ្ញវត្ថុ"** សូមអាននៅទំព័រ...............៨


## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចគណនេយ្យនិងសវនកម្មនិងបទប្បញ្ញត្តិពាក់ព័ន្ធ"សម្រាប់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញតាមប្រព័ន្ធអនឡាញ (ZOOM)



១.កាលពីព្រឹកថ្ងៃអង្គារ៍៨រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹង ថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចគណនេយ្យនិងសវនកម្មនិងបទប្បញ្ញត្តិពាក់ព័ន្ធ"សម្រាប់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញតាមប្រព័ន្ធអនឡាញ(ZOOM)។ សិក្ខាសាលានេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក លី កុសល** អនុប្រធានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការគតិយុត្ត និងអនុលោមភាព និងមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម ព្រមទាំងវត្តមានរបស់តំណាងសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញចំនួន ៣៥០នាក់។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយនិងបញ្ជ្រាបការយល់ដឹងអំពីកាតព្វកិច្ចគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជូនដល់ នាយកក្រុមហ៊ុន សហគ្រាស ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងអ្នកដែលមានការទទួលខុសត្រូវលើកិច្ចការ ការងារគណនេយ្យ។

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

## កិច្ចប្រជុំជាមួយតំណាងអគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានពន្ធដារ




២.កាលពីព្រឹកថ្ងៃព្រហស្បតិ៍ ១១រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤ នៅបន្ទប់ប្រជុំធំរបស់ ន.គ.ស. **លោក សេង តុលា** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយមន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេសបាន ដឹកនាំកិច្ចប្រជុំជាមួយតំណាងអគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានពន្ធដារ ដើម្បីពិនិត្យនិងពិភាក្សាលើ"សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃចំណូលសារពើពន្ធ"។

## កិច្ចប្រជុំការងារបច្ចេកទេសនៃអង្គភាពក្រោមឱវាទ អ.ស.ហ.




៣.កាលពីល្ងាចថ្ងៃព្រហស្បតិ៍ ១១រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនីយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក ទឹម សត្យា**, អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ, **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស និង **លោកស្រី ហា សុគន្ធា** ប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ បានអញ្ជើញចូលរួមកិច្ចប្រជុំបច្ចេកទេស នៃអង្គភាពក្រោមឱវាទ អ.ស.ហ. ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា អ.ស.ហ.។ គោលបំណងនៃកិច្ចប្រជុំគឺដើម្បីពិនិត្យ និងផ្តល់យោបល់លើឯកសារដូចខាងក្រោម៖

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

១. សេចក្តីព្រាងរបាយការណ៍សមិទ្ធផលឆ្នាំ២០២៣ របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
២. របាយការណ៍ត្រួតពិនិត្យការអនុវត្តថវិកាប្រចាំឆ្នាំ២០២៣ របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
៣. ផ្សេងៗ

## កិច្ចប្រជុំជាមួយតំណាងក្រុមហ៊ុនគណនេយ្យនិងសវនកម្ម




៤.កាលពីរសៀលថ្ងៃព្រហស្បតិ៍ ១១ រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤ **លោក ជេន ផាត** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ នៃនាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម បានដឹកនាំកិច្ចប្រជុំជាមួយតំណាង ក្រុមហ៊ុនគណនេយ្យនិងសវនកម្ម ដើម្បីពិភាក្សាលើ "ការវាយតម្លៃថ្នាក់ជាតិសម្រាប់ម៉ូឌុលទី៧៖ DNFBPs និងផែនការសកម្មភាព សម្រាប់អនាគត (វិស័យគណនេយ្យនិងសវនកម្ម)" នៅសណ្ឋាគារសាន់វេភ្នំពេញ ក្នុងគោលបំណងដើម្បីក្រើនរំលឹកដល់ក្រុមហ៊ុនគណនេយ្យនិងសវនកម្ម ដែលជាបុគ្គលរាយការណ៍ក្នុងវិស័យគណនេយ្យនិងសវនកម្ម អោយយកចិត្តទុកដាក់លើអនុលោមភាព តាមច្បាប់ស្តីពីការប្រឆាំងការសម្អាតនិងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (AML&CFT និង CPF) ដែលសមត្ថភាពនៃអនុលោមភាព គឺជាមូលដ្ឋាននៃការវិភាគក្នុងការសម្រេចចិត្តដាក់ពិន្ទុឱ្យ variable ទាំង ១២ ដើម្បីរៀបចំរបាយការណ៍ផ្ញើជូន អ.ស.ហ.។ សមាជិកចូលរួមកិច្ចប្រជុំនេះមានចំនួន ៧៧រូប មកពីក្រុមហ៊ុន គណនេយ្យនិងសវនកម្ម ចំនួន ៦៥ក្រុមហ៊ុន) ។

## កិច្ចប្រជុំពិភាក្សាស្តីពីការបង្ហាញ "ការបង្វិលសងអាករលើតម្លៃបន្ថែម (VAT Refund) ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ"



៥.កាលពីព្រឹកថ្ងៃព្រហស្បតិ៍ ១០កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក ទឹម សត្យា** អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ និងមន្ត្រីជំនាញបានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការបង្ហាញ "ការបង្វិលសងអាករលើតម្លៃបន្ថែម (VAT Refund) ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ"។ កិច្ចប្រជុំនេះដឹកនាំដោយ **ឯកឧត្តមបណ្ឌិតសភាចារ្យ ជូ វិជិត្ត** រដ្ឋលេខាធិការប្រចាំការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## វគ្គបណ្តុះបណ្តាលស្តីពី"ស្តង់ដារបាយការណ៍ទាក់ទងនិងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុន តូចនិងមធ្យម" CIFRS for SMEs




៦.កាលពីរសៀលថ្ងៃចន្ទ ១៤កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៤ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រី នៃនិយ័តករគណនេយ្យនិងសវនកម្ម បានចូលរួមបិទវគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម" ដែលបានរៀបចំឡើងក្នុងរយៈពេល៦ថ្ងៃ ចាប់ពីថ្ងៃទី២៥-២៦ ខែមីនា និង ថ្ងៃទី៨-៩-១០-២២ ខែមេសា ឆ្នាំ២០២៤។ ក្នុងនោះផងដែរ **ឯកឧត្តមអគ្គនាយក** ក៏បានគូសបញ្ជាក់ផងដែរថាគោលបំណងរបស់និយ័តករគឺចង់បានការប្រកាន់ខ្ជាប់នូវ “វប្បធម៌គណនេយ្យ” ដែលមានជាអាទិ៍វប្បធម៌កាន់បញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ, វប្បធម៌រៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាជាធរមាន, វប្បធម៌ដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ និងវប្បធម៌ដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមកនិយ័តករគណនេយ្យនិងសវនកម្ម។ **ឯកឧត្តមអគ្គនាយក** ក៏បានបន្ថែមផងដែរថាការដាក់ទោសទណ្ឌឬពិន័យដល់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ មិនមែនជាបំណងប្រាថ្នាចម្បងរបស់ និយ័តករគណនេយ្យនិងសវនកម្ម នោះទេ។ មុននឹងបញ្ចប់ **ឯកឧត្តមអគ្គនាយក** បានជូនពរ ដល់សិក្ខាកាមទាំងអស់ទទួលបានជោគជ័យក្នុងការប្រឡងជាពិសេសមានសុខភាពល្អ កម្លាំងពលំមាំមួន មានសុភមង្គលក្នុងគ្រួសារ។

## ជួបសម្តែងការគួរសមនិងពិភាក្សាការងារជាមួយគណៈប្រតិភូសាកលវិទ្យាល័យពាណិជ្ជសាស្ត្រអេស៊ីលីដា




© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

៧.កាលពីព្រឹកថ្ងៃអង្គារ ១៥ កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក លោកស្រី** អគ្គនាយករង ថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម បានអញ្ជើញជួបសម្តែងការគួរសមនិងពិភាក្សាការងារជាមួយគណៈប្រតិភូសាកលវិទ្យាល័យពាណិជ្ជសាស្ត្រអេស៊ីលីដា ដឹកនាំដោយ **លោកបណ្ឌិត ផុន ណារិន** សាកលវិទ្យាធិការដែលបានប្រព្រឹត្តទៅនៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ អំឡុងពេលនៃជំនួបភាគីទាំងពីរបានពិភាក្សាពីការចុះអនុស្សរណៈនៃការយោគយល់គ្នារវាង និយ័តករគណនេយ្យនិងសវនកម្ម និងសាកលវិទ្យាល័យពាណិជ្ជសាស្ត្រអេស៊ីលីដា ក្នុងគោលបំណងចែករំលែកបទពិសោធន៍និងធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាដែលអាចបំពេញតម្រូវការរបស់ស្ថាប័នរដ្ឋ និងឯកជនជូនដល់និស្សិតប្រកបដោយប្រសិទ្ធភាពខ្ពស់។

## កិច្ចប្រជុំពិភាក្សាទ្វេភាគីជាមួយក្រុមការងារ "ឍ" សេវាហិរញ្ញវត្ថុមិនមែនធនាគារ ផ្នែកឯកជននៃសភាពាណិជ្ជកម្មកម្ពុជា



៨.កាលពីព្រឹកថ្ងៃពុធ ១ រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤ នៅអគារ ៣៤៥ និយ័តករគណនេយ្យនិងសវនកម្ម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគា អមដោយ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម ព្រមទាំង លោក លោកស្រី អគ្គនាយករង, ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ នៃ ន.គ.ស. បានប្រជុំពិភាក្សាទ្វេភាគីជាមួយក្រុមការងារ "**ឍ**" សេវា ហិរញ្ញវត្ថុមិនមែនធនាគារ ផ្នែកឯកជននៃសភាពាណិជ្ជកម្មកម្ពុជាដឹកនាំដោយ **ឧកញ៉ា លឹម សុជាតិ** អមដោយគណៈប្រតិភូនៃសភាពាណិជ្ជកម្មកម្ពុជា ដើម្បីពិនិត្យលើ“**សេចក្តីព្រាងអនុក្រឹត្យស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើស នឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម**”។ កិច្ចប្រជុំនេះរៀបចំឡើងក្នុងគោលបំណងដើម្បីពិនិត្យលើសេចក្តីព្រាង អនុក្រឹត្យនេះបន្ទាប់ពីបានកែសម្រួលតាមសំណូមពររបស់សភាពាណិជ្ជកម្មកម្ពុជា កាលពីកិច្ចប្រជុំពិភាក្សាទ្វេភាគីនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ កន្លងទៅ។ សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះសរុបប្រមាណ ៧០នាក់។

## កិច្ចប្រជុំស្តីពីការបូកសរុបការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៤



៩.កាលពីថ្ងៃព្រហស្បតិ៍២រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំកិច្ចប្រជុំស្តីពីការបូកសរុបការងារប្រចាំត្រីមាសទី១ ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ លោក លោកស្រី អគ្គនាយករង និងមានការអញ្ជើញចូលរួមពី លោក លោកស្រី អនុប្រធាននាយកដ្ឋាន ព្រមទាំងមន្ត្រីក្រោមឱវាទទាំងអស់របស់ ន.គ.ស ដែលប្រព្រឹត្តទៅនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## កិច្ចប្រជុំបច្ចេកទេសបន្តជាមួយក្រុមហ៊ុន Big4 និងវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា




១០.កាលពីព្រឹកថ្ងៃសុក្រ ៣ រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្មអមដោយ អគ្គនាយករង, ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ នៃ ន.គ.ស. បានដឹកនាំកិច្ចប្រជុំបច្ចេកទេសបន្តជាមួយក្រុមហ៊ុន Big4 និងវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើ “សេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងគុណភាពសវនកម្ម និងការអះអាង” តាមប្រព័ន្ធអនឡាញ (Zoom)។

## សិក្ខាសាលាផ្សព្វផ្សាយ “ប្រកាសស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម និងការស្នើសុំអាជ្ញាបណ្ណតាមប្រព័ន្ធអនឡាញ” លើកទី៣



១១.កាលពីព្រឹកថ្ងៃចន្ទ ៦រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ នៅសណ្ឋាគារភ្នំពេញ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម បានបើកសិក្ខាសាលាផ្សព្វផ្សាយ “ប្រកាសស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម និងការស្នើសុំអាជ្ញាបណ្ណតាមប្រព័ន្ធអនឡាញ” លើកទី៣ ដែលមានការចូលរួមដោយ **លោកស្រី នាន បូនី** អគ្គនាយករង នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ស៊ុន វុទ្ធី** នាយកសាលាជាតិពន្ធដារ **លោក ឃុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សានៃវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ថ្នាក់ដឹកនាំ និងមន្ត្រីនិយ័តករគណនេយ្យនិងសវនកម្ម ថ្នាក់ដឹកនាំ និងមន្ត្រីតំណាងសាលាជាតិពន្ធដារ តំណាងពីអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

និយ័តករធានារ៉ាប់រងកម្ពុជា និយ័តករមូលបត្រកម្ពុជា និយ័តករសន្តិសុខកម្ពុជា និយ័តករបរធនបាលកិច្ច និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ អង្គភាពសវនកម្មផ្ទៃក្នុង នៃ អ.ស.ហ. ថ្នាក់ដឹកនាំរបស់ វ.គ.ស.ក. និងមានការចូលរួមពីប្រធាន ឬតំណាងក្រុមហ៊ុនគណនេយ្យនិងសវនកម្ម ដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ពី ន.គ.ស. ភ្នាក់ងារសេវាកម្មពន្ធដារ និងសាធារណៈជនសរុបប្រមាណ ២២៥នាក់។

## កិច្ចប្រជុំពិភាក្សាស្តីពីការកត់ត្រាការបង្វិលសងអាករលើតម្លៃបន្ថែម(VAT Refund)



១២.កាលពីរសៀលថ្ងៃចន្ទ ៦រោច ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម, **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេសអមដោយមន្ត្រីជំនាញបានចូលរួមកិច្ចប្រជុំពិភាក្សាស្តីពី ការកត់ត្រាការបង្វិលសងអាករលើតម្លៃបន្ថែម (VAT Refund) ដែលដឹកនាំដោយ **ឯកឧត្តមបណ្ឌិត វង្ស ប៊ុនឥន្ទ្រាវុធ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ និងការចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីជំនាញតំណាងរបស់អគ្គនាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅសាលប្រជុំនៃអគ្គនាយកដ្ឋានរតនាគារជាតិ។

## កិច្ចពិភាក្សាប្រចាំឆ្នាំ និងលក្ខខណ្ឌតម្រូវដើម្បីក្លាយជាសមាជិកពេញសិទ្ធរបស់សហព័ន្ធគណនេយ្យករអន្តរជាតិ



១៣.កាលពីរសៀលថ្ងៃចន្ទ ៦ រោច ខែចេត្រ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ នៅវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក**

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃនាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាស្តីពី៖ របៀបវារៈនៃកិច្ចពិភាក្សាប្រចាំឆ្នាំ និងលក្ខខណ្ឌតម្រូវដើម្បីក្លាយជាសមាជិកពេញសិទ្ធ របស់សហព័ន្ធគណនេយ្យករអន្តរជាតិ។

## កិច្ចពិភាក្សាជាមួយសមាគមធានារ៉ាប់រងកម្ពុជាស្តីពីផែនការសកម្មភាពអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាលេខ១៧ “កិច្ចសន្យាធានារ៉ាប់រង” និងលេខ៩ “ឧបករណ៍ហិរញ្ញវត្ថុ”



១៤.កាលពីព្រឹកថ្ងៃអង្គារ ៧រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ នៅអាគារ៣៤៥ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី នាន បូនី** អគ្គនាយករងថ្នាក់ដឹកនាំ បានដឹកនាំកិច្ចពិភាក្សាជាមួយសមាគមធានារ៉ាប់រងកម្ពុជាស្តីពីផែនការសកម្មភាពអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាលេខ១៧ “កិច្ចសន្យាធានារ៉ាប់រង” និង លេខ៩ “ឧបករណ៍ហិរញ្ញវត្ថុ” និងវឌ្ឍនភាពការងារ នៃការអនុវត្តផែនការសកម្មភាពលម្អិតរបស់ក្រុមហ៊ុនធានារ៉ាប់រងស្របតាមសេចក្តីជូនដំណឹងលេខ ០០១២/២៣ ន.គ.ស/ស.ជ.ណ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣។

រៀបចំដោយ÷**លោក ឡាយវិ ចិត្រ**

អ្នកសម្របសម្រួលអត្ថបទ÷**កញ្ញា សុខ ណារី**